ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ............ ព.ណ..........

# សេចក្តីណែនាំ

## ស្តីពី

## ការផ្អាកការស្កេនមេដៃចុះវត្តមាន របស់មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម

យោងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសំណេះសំណាលជាមួយគ្រូពេទ្យស្ម័គ្រចិត្តចូលរួមប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ១៩ នៅវិមានសន្តិភាពនាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ និងយោងតាមសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្មស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាមន្ត្រីរាជការក្រោមឱវាទទាំងអស់ មេត្តាជ្រាបថា៖ ដើម្បីចូលរួមប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរីករាលដាល ការឆ្លងនៃជំងឺកូវីដ១៩ តាមរយៈការកាន់ ការពុច ឬការប៉ះពាល់នូវវត្ថុផ្សេងៗបន្តបន្ទាប់គ្នា ក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអគ្គនាយក អគ្គាធិការស្តីទី ប្រធាន ប្រធានស្តីទីនាយកដ្ឋាន ប្រធានវិទ្យាស្ថាន និងប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំងអស់ សូមធ្វើការផ្អាកនូវការស្កេនមេដៃចុះវត្តមាន របស់មន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន ទាំងម៉ោងចូល-ចេញ ចាប់ពីថ្ងៃនេះរហូតដល់មានសេចក្តីណែនាំថ្មី ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការក្រោមឱវាទទាំងអស់ មេត្តាជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469